# ការសំភាសន៍របស់អ៊ុំស្រី តី សំណាង

ក៖ អ្នកដែរសំភាសន៍គេ ជាង ស៊ីអ៊ារ ខ៖ អ្នកដែរអោយគេសំភាសន៍ តី សំណាង

ក៖ ចឹងជាដំបូងខ្ញុំអរគុណអ៊ុំដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង ប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍អ៊ុំ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់អ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខ៖ ចា៎!!ព្រមតើលោកគ្រូមានទៅស្អី កុំអោយតែពាក់ពន្ធតែយើងទៅបានហើយ

ក៖ អត់មានអីទេអ៊ុំ

ខ៖ ចា៎!!អត់មានអីផង

ក៖ បាទអ៊ុំបាទ?

ខ៖ ចុះយើងគ្មានយកប្រទេសជាតិមកនិយាយណា

ក៖ បាទអ៊ុំយើងនិយាយតែប្រវត្តិរបស់យើងផ្ទាល់ខ្លួន

ខ៖ យើងនិយាយតើពីប្រវត្តិរបស់យើងផ្ទាល់ខ្លួន

ក៖ បាទអ៊ុំបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អ៊ុំគឺនៅថ្ងៃទី22ខែ3 ឆ្នាំ2018 ចឹងភូមិនឹងអ៊ុំអត់ស្គាល់ទេណអ៊ុំ?

ខ៖ គេហៅថាភូមិបឹងសាឡាង

កៈ ភូមិបឹងសាឡាង ចុះសង្កាត់?

ខៈ និយាយចឹងតែម្តងទៅ សង្កាត់នឹងសង្កាត់បឹងសាឡាងនឹង
ភូមិនឹងមិនមែនជាភូមិបឹងសាឡាងទេប៉ុន្តែ គេបានហៅថាបឹងសាឡាងនឹងតែម្តងនឹង

កៈ ប៉ុន្តែសង្កាត់នឹងសង្កាត់បឹងសាឡាងនឹង?

ខៈ ចា៎!!ប៉ុន្តែយាយបើអាអូនអ្នករៀននឹងវាស្គាល់ភូមិនឹង
ហើយវាដឹងទាំងផ្លូវដឹងអីទាំងអស់នឹងបើវាណាស់

កៈ បាទអ៊ុំបាទ?

ខៈ ចា៎!!បើយាយមិនសូវជាចងចាំទេ

កៈ ចុះខ័ណ្ឌអីគេដែរអ៊ុំ?

ខៈ នឹងខ័ណ្ឌទួលគោកទេអី

កៈ ចឹងខ័ណ្ឌទួលគោកណាអ៊ុំ?

ខៈ ប្រហែលជាចឹងហើយយ៉ាង គ្រាន់តែប្រហែលទេមិនសូវជាច្បាស់ទេ

កៈ នឹងហើយអ៊ុំនៅរាជធានីភ្នំពេញ

ខៈ នឹងហើយនៅរាជធានីភ្នំពេញ

កៈ ចឹងសំរាប់អ៊ុំឈ្មោះពេញរបស់អ៊ុំនឹងមានឈ្មោះអីគេដែរអ៊ុំ?

ខៈ ខ្ញុំឈ្មោះសំ ណាង

កៈ ឈ្មោះអីគេសំណាងទៅអ៊ុំ?

ខៈ មានឈ្មោះតី សំណាង

កៈ ឈ្មោះទេ សំណាង?

ខៈ ឈ្មោះតី សំណាង

កៈ អ៊ូ!!ឈ្មោះតី សំណាងនឹងចុះមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ គេហៅខ្ញុំតែប៉ុណ្ណឹងហៅតែសំណាងៗៗនឹងប៉ុន្តែភាគច្រើននឹងគេហៅខ្ញុំយាយពោត

ក៖ អូ៎!!យាយពោត យាយលក់ពោតហីអ៊ុំ?

ខ៖ យាយលក់ពោតនឹងហាស

ក៖ អូ៎!!បាទអ៊ុំ ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះអីផ្សេងទៀតទេអ៊ុំ?

ខ៖ អត់មានទេ

ក៖ ចឹងមានតែឈ្មោះសំ ណាងនឹងមួយទេ?

ខ៖ ចាំ!!មានតែឈ្មោះសំ ណាងនឹងមួយទោះនៅស្រុកក៏ដោយ មកនឹងក៏ដោយ

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ខ្ញុំមិនដែរមានឈ្មោះពីរបីផងនឹង

ក៖ ចុះដូចជាសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំអាយុ57ឆ្នាំហើយអូន

ក៖ ប៉ុន្តែអ៊ុំកើតនៅថ្ងៃខែឆ្នាំណាដែរអ៊ុំមានចងចាំទេ?

ខ៖ អត់ចងចាំទេកូនអើយនិយាយពីថ្ងៃខែឆ្នាំកំណើតនឹងចប់ ចប់តែម្តងនឹង

ក៖ ចុះឆ្នាំក៏អ៊ុំអត់ដឹងដែរណាអ៊ុំ?

ខ៖ បើឆ្នាំយើងខ្មែរនឹងដឹងអូន ប៉ុន្តែឆ្នាំគេហៅសកលនឹងអត់ដឹងទេ

ក៖ អូ៎!!កើតនៅឆ្នាំ1961

ខ៖ ចឹងអីណាទាល់គេអ្នកចេះចឹងហាស ចុះបើដូចជាយាយអត់ចេះចឹងធ្វើយ៉ាងម៉េចដែរ?

ក៖ ចុះថ្ងៃខែក៏អ៊ុំអត់មានចងចាំដែរណាអ៊ុំ?

ខ៖ អត់ទាំងអស់

ក៖ ចុះលក្ខណះថាឆ្នាំជូត ឆ្លូវ ខាល ថោះនឹងអ៊ុំឆ្នាំអីគេដែរអ៊ុំ?

ខ៖ ខ្ញុំឆ្នាំថោះនឹងហាស

កៈ ចឹងអ៊ុំឆ្នាំថោះណាអ៊ុំ ចុះអ៊ុំកើតនៅណាដែរអ៊ុំ?

ខៈ ខ្ញុំកើតនឹងវែងឆ្ងាយណាស់អូន
ព្រោះអីកាលពីជំនាន់ខ្ញុំនឹងណោះខ្ញុំនៅយើងនៅផ្លូចជាលេខ5ហោស

កៈ ចឹងអ៊ុំកើតនៅផ្លូវជាតិលេខ5?

ខៈ ចាំ!!នៅភូមិទឹកល្អក់នឹងនៅមិនដល់យើងផ្សារព្រែកខ្មែរទេ ភូមិយើងនឹងហាស

កៈ បាទអ៊ុំបាទ?

ខៈ ប៉ុន្តែខ្ញុំរស់នៅនឹងខ្ញុំកំព្រាម្តាយកំព្រាឪពុក ខ្ញុំកើតមកនឹងអត់មានឃើញឪពុកទេ
ខ្ញុំឃើញតែម្តាយនឹង
ដល់ពេលដែរខ្ញុំអាយុបាន5ឆ្នាំនឹងម្តាយរបស់ខ្ញុំនឹងស្លាប់ចោលទៀតខ្ញុំរស់នៅជាមួយជីដូន

កៈ ចឹងមានន័យថាពួកគាត់ស្លាប់នឹងកាលអ៊ុំនៅតាំងពីក្មេងៗៗ?

ខៈ នៅជំនាន់អ៊ីសារ៉ាក់អីណោះកូនតាំងពីខ្ញុំនៅក្នុងពោះបាន7ខែណោះ

កៈ អ្ហ៎!!បាទអ៊ុំបាទ?

ខៈ អត់បានឃើញឪពុកទេដល់ពេល

កៈ ប៉ុន្តែនៅភូមិឃុំនឹងអ៊ុំមានដឹងអត់

ខៈ ខ្ញុំកាលណុងយើងគ្រាន់តែដឹងនៅភូមិទឹកល្អក

កៈ នៅភូមិទឹកល្អកប៉ុន្តែនៅឃុំអីគេដែរអ៊ុំ?

ខៈ អត់ដឹងឃុំទេចុះនៅតូចនឹងអត់មានចងចាំអីផងនឹង

កៈ ប៉ុន្តែស្រុកកាលណុងអ៊ុំអត់មានដឹងថានៅស្រុកអីទេ?

ខៈ ស្រុកនឹងកាលណុងគេប្រើស្រុកស្អីទេនេះ ប៉ុន្តែដឹងតែខេត្តនឹង

កៈ នៅខេត្តកណ្តាលនឹង?

ខៈ មិនមែនទេ

កៈ នៅខេត្តកំពង់ស្ពឺហីអ៊ុំ?

ខ៖ នៅខេត្តកំពង់ឆ្នាំងនឹង

ក៖ នៅខេត្តកំពង់ឆ្នាំងហោសអ៊ំ?

ខ៖ ចា៎!!ខ្ញុំនៅខាងផ្លូវជាតិលេខ5ហោសដល់វែងឆ្ងាយណាស់អូន
រស់នៅជាមួយយាយចឹងទៅ រស់នៅជាមួយមីងចឹងទៅ
ដល់ពេលដែរមីងការអស់ចឹងទៅខ្ញុំនៅជាមួយយាយ ដល់ដឹងយ៉ាងម៉េចទេនឹង
ម្ដាយបានស្លាប់ចោលហើយនឹង
ដល់ពេលដែរទៅនៅជាមួយយាយទៅទទួលស្រុកនឹងវាកើតសង្គ្រាម នឹងតែម្ដងនឹង

ក៖ ប៉ុន្ដែនៅឆ្នាំណាដែរអ៊ំ?

ខ៖ មុនទំលាក់តាសម្ដេចហាសអូនឆ្នាំ1970 រឺក៏ឆ្នាំប៉ុន្មានដែរ ដូចជាឆ្នាំ1971រឺឆ្នាំ1972-1970ទេដឹងហី

ក៖ ប្រហែលជាឆ្នាំ1970នឹងអ៊ំ?

ខ៖ ដូចជាឆ្នាំ1970គត់ទេអូនកាលណុងខ្ញុំនៅអាយុ5ឆ្នាំនឹងហោស

ក៖ បាទអ៊ំបាទ?

ខ៖ ប៉ុន្ដែខ្ញុំនឹងអាចចងចាំបានច្រើន

ក៖
អ៊ំអាយុ5ឆ្នាំចឹងមានន័យថាអ៊ំអាយុ65ឆ្នាំនឹងអ៊ំដោយសារតែអ៊ំអាយុ5ឆ្នាំហើយអ៊ំកើតនៅឆ្នាំ1961?

ខ៖ ឥឡូវនឹងអី?

ក៖ បាទអ៊ំ

ខ៖ អត់ទេអូនអាយុ57ឆ្នាំទេអូន

ក៖ អត់ទេនិយាយថាឆ្នាំ1965នឹងគេទើបតែចាប់ផ្ដើមទំលាក់សម្ដេចហាស?

ខ៖ នឹងហើយគេទំលាក់សម្ដេចនឹងគេដាក់ទាហ៊ានតាមផ្ទះ
ហើយទទួលទៅប្រជាជនយើងនឹងហាសអូន

យាយរបស់ខ្ញុំនឹងអត់ធ្វើស្រែទេជួលគោជួលអោយគេចឹងទៅ
តារបស់ខ្ញុំក៏អត់នៅមីងរបស់ខ្ញុំនឹងក៏មានប្ដី
ទៀតក៏ជួលគោអោយគេក៏លក់ជាអាកោមានជានុំបញ្ចុះ
រស់នៅពីរនាក់ខ្ញុំនឹងមានដូចស្វាយអីមានច្រើន
ណាស់ចឹងទៅក៏នៅៗៗទៅនៅជិតត្រង់ភូមិរបស់ខ្ញុំនឹងគេបានដាក់បន្ទាយទាហ៊ាន
ដល់ពេលដែរបន្ទាយ ទហ៊ាននឹងទៅក៏វៃបាក់ទ័ពហាសអូន ក៏រត់ទៅ

កៈ រត់ទៅណាដែរទៅអ៊ុំ?

ខៈ រត់ចោលផ្ទះរត់នឹងរត់ទៅពួននៅឡគេជីកធ្យូងហាសអូន

កៈ នៅណាដែរអ៊ុំ?

ខៈ នៅក្នុងព្រៃហាស

កៈ នៅក្នុងព្រៃប៉ុន្តែនៅក្នុងខេត្តកំពង់ឆ្នាំងនឹងដដែរនឹង?

ខៈ នៅក្នុងខេត្តកំពង់ឆ្នាំងនឹងដដែរនឹងអត់ទាន់បានជំលាស់ចេញទេណាស់

កៈ បាទអ៊ុំបាទ?

ខៈ ខ្ញុំទៅនៅក្នុងឡនឹងកាំភ្លើងធំកាំភ្លើងតូចផ្លោងនឹងចេះតែរស់មកដល់ឥឡូវនឹង

កៈ ប៉ុន្តែនៅណុងឆ្នាំណាដែរវិញអ៊ុំ នៅជំនាន់ពលពតរឺក៏មិនមែនដែរអ៊ុំ?

ខៈ មុនពលពតនឹងហើយ

កៈ មុនពលពតនឹងចឹងមានន័យថានៅឆ្នាំលុនណុលណអ៊ុំ?

ខៈ
មុនលុនណុលជាអ្នកបង្កើតសង្គមនឹងលុនណុលហើយប៉ុន្តែប្រជាជនមានសិទ្ធិនៅក្នុងក្រៅ
ចេះនឹង

កៈ អ៊ូ!!ចឹងអាចចេញចូលបាន?

ខៈ នៅចេញចូលបានប៉ុន្តែវានៅជំនាន់ណុងហាសវាមិនទាន់បិទទេ

កៈ បាទអ៊ុំបាទ?

ខ៖ 
ដល់ពេលដែរទាហ៊ានបាក់ទ័ពអស់យាយទាំងយាយទាំងខ្ញុំនឹងបានរត់ចោលស្រែចោលអីចឹងណាស់ អូនហើយ

ក៖ បាទអុំបាទ?

ខ៖ រត់ចោលនឹងមកនៅទីក្រុងភ្នំពេញនឹងមកនៅនឹង

ក៖ ប៉ុន្តែមកនៅនឹងនៅឆ្នាំណាដែរអុំ?

ខ៖ មកនៅនឹងយើងឆ្នាំ1974ហើយ

ក៖ នៅឆ្នាំ1974ហើយចឹងមានន័យថាជិតដល់ចូលពលពតហើយណាអុំ?

ខ៖ នៅជិតចូលហើយដល់ពេលដែរមកនៅឆ្នាំ1974ហើយនឹង
ហើយក៏យាយខ្ញុំនឹងមានកូនប្រុសមួយ
នៅធ្វើជាទាហ៊ានកាលណុងវានៅតូចនឹងនៅក្នុងភ្នំពេញនេះនឹង

ក៖ បាទអុំបាទ?

ខ៖ នៅផ្ទះយាយរបស់ខ្ញុំនឹងនៅក្បែរអូរឡាំពេចនឹង
ក៏ចេះតែដើរលេងជាមួយបងប្អូនទៅចុះក្មេងវា
សប្បាយហាសទៅនៅបន្ទាយចោមចៅនឹងវាក្តៅ

ក៖ ចុះម៉េចចឹងបានជាក្តៅចឹងហាសអុំ?

ខ៖ ចុះបន្ទាយទាហ៊ាននឹង

ក៖ អូ៎!!!ចឹងទេ?

ខ៖ បន្ទាយទាហ៊ានគេលើរបងខ្ពស់ណាស់គេលើករបង
ចុះទៅគេដាក់មីនគេដាក់គំរោងចឹងទៅណាស់

ក៖ បាទអុំបាទចឹង?

ខ៖ បន្ទាយទាហ៊ាននឹងធំណាស់អូនដល់ហើយយាយអត់ទៅទេ
យាយនៅតែភ្នំពេញនឹងដល់ជិតបែកនឹង

ហាសយាយរបស់ខ្ញុំជីដូនមួយនឹងក៏អោយខ្ញុំយកតវ៉ាន់នឹងទៅជូនយាយបង្កើតនឹងហាសអត់មានដឹងថាបែកណា ដល់ពេលដែរបែកនឹងដូចជា17មេសាចឹងហើយយ៉ាងចឹងហើយបានបែកពីភ្នំពេញនឹងថ្ងៃទី17មេសានឹង ដល់កាលណុងវារៀងយូរដែរកាលណុងខ្ញុំបានភ្លេសអស់ហើយអូនវារៀងយូរដែរនឹង

ក៖ អូ៎!!ចឹងហោសអ៊ុំ?

ខ៖ ចេញទៅពេលមកវិញក៏គេមិនអោយចូលផ្ទះវិញភ្នំពេញនឹងហាសជាអ្នកជំលាស់ពួកខ្ញុំចេញហាស ពីផ្ទះសំបែងបងប្អូននឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ នៅចោលណោះមួយកន្លែងមកនៅនេះគេចោលទៀតគេអោយយើងនឹងចេញទៀតអូនចេញនឹងគេថាអត់អោយយើងយកអីទេណាស់

ក៖ ចឹងចេញតែខ្លួនអ៊ុំ?

ខ៖ ចេញតែខ្លួនទេ ចេញតែចំងាយតែ15គីឡូទេ រឺក៏10គីឡូទេនេះចេញពីក្រុងហាសអូនដល់ពេលដែរចេញទៅនឹងវាបញ្ជូនយើងទៅ អត់អោយទៅនៅព្រៃកថ្មីគគីធំយើងនឹងទេនោះវាបំបែកអោយទៅនៅណាៗៗអូនអើយវេទនា

ក៖ ប៉ុន្តែយើងអត់ស្គាល់ទេណអ៊ុំ?

ខ៖ យើងអត់ស្គាល់ទេហើយពួកខ្ញុំនឹងសុទ្ធតែប្រជាជនថ្មីទាំងអស់នឹងកាលណុងមានពីរបក្សហាស

ក៖ ប៉ុន្តែអត់អីទេ?

ខ៖ មានប្រជាជនថ្មីនឹងប្រជាជនចាស់

ក៖ ប្រជាជនថ្មីនឹងមានប៉ុន្មានគ្រួសារទៅអ៊ុំទៅរស់នឹង?

ខ៖ ទាំងអស់គ្រួសារបងប្អូនរបស់ខ្ញុំនឹងឥឡូវនឹងគេសំលាប់ចោលអស់ហើយនឹង

កៈ អូ៎!!បាទអ៊ុំ?

ខៈ
គេសំលាប់ចោលអស់ហើយនឹងអូនប្រជាជនថ្មីនឹងពួកខ្ញុំនឹងមកនៅភ្នំពេញនឹងទាំងអស់នឹង
ដល់ពេលដែរចេញនឹងចេញទៅទាំងអស់នឹង

កៈ បាទអ៊ុំបាទ?

ខៈ ដល់ពេលអ្នកដែរប្រជាជនចាស់នឹងគេនៅក្នុងភូមិ នឹងគេប្រជាជនចាស់ហាសអូនទៅ
យើងនឹងប្រជាជនថ្មីនឹងអត់មានសិទ្ធិទេគេអោយហូបចុងអង្ករនឹងកន្លះខាំ
ពោហាវែគ្រាប់យើងប៉ុណ្ណឹងៗៗ
មួយខាំក្នុងមួយថ្ងៃហាសអូនថាខ្ញុំវេទនាណាស់អូនអើយវេទនាណាស់

កៈ ប៉ុន្តែកាលណុងនៅជំនាន់ពលពតមែនអ៊ុំ?

ខៈ នឹងហើយចូលជំនាន់ពលពតហើយនឹងទើបតែចូលទេនឹងហោស
អត់ទាន់បានកាន់កាប់យើងពេញ តំលៃទេនឹងហោស

កៈ ប៉ុន្តែគេជំលាស់អ៊ុំទៅណុងនឹងគេអោយអ៊ុំធ្វើអីគេដែរទៅអ៊ុំ?

ខៈ គេអោយលើកភ្លឺស្រែ
គេអោយលើកភ្លឺស្រែនឹងនៅក្នុងខេត្តកណ្តាលនឹងហាសដល់ពេលហើយខ្ញុំរត់

កៈ អ៊ុំរត់ទៅណាដែរ?

ខៈ
ខ្ញុំឃ្លានពេកនឹងខ្ញុំរត់ទៅខេត្តស្វាយរៀងខ្ញុំរស់នៅទាល់តែឥឡូវនឹងតើអូនទាល់តែចាស់ស្មែ
ងវែងជា នឹងទៅណាស់អូន

កៈ ចុះគេអត់ថាអីទេហោសអ៊ុំ?

ខៈ អូនហោបើអូនលឺបានអូនដឹងថាវេទនាប៉ុណ្ណាតើយាយនិយាយនឹងយាយយំរហូតនឹង
កាលណុងអើរវាធំហើយណាស់អូនណាស់

កៈ បាទអ៊ុំបាទ?

ខ៖ ខ្ញុំអាយុ12ឆ្នាំអីហើយមើលណាស់ ខ្ញុំរត់ទៅរត់ពីនឹងទៅទៅឆ្លងង្អកលៀនហើយណាស់ដល់ពេលដៃរចៃដន្យនឹងចេះទៅជួបគេ
គេបានប្តូរទៅលំនៅហាសហើយខ្ញុំសុំគេប្តូរឈ្មោះជាកូន

ក៖ បាទអ៊ុំបាទ?

ខ៖ ចុះយើងនៅតូចៗសុំគេចុះឈ្មោះជាកូនគេដាក់អោយទៅដល់ទឹកដី

ក៖ ទៅដល់ខេត្តស្វាយរៀងហោស?

ខ៖ ទៅដល់ខេត្តស្វាយរៀងខ្ញុំបានរត់ចោលគេទៀត

ក៖ ប៉ុន្តែអ៊ុំចុះឈ្មោះជាកូនទៅចុះឈ្មោះពីណា?

ខ៖ ទៅបានគេអោយយើងទៅបើចឹងគេបាញ់យើង

ក៖ ប៉ុន្តែនៅក្នុងគ្រួសារនរណាគេ?

ខ៖ នៅក្នុងគ្រួសារគេ

ក៖ ប៉ុន្តែយើងអត់ដែរស្គាល់គេទេ?

ខ៖ យើងអត់ដែរស្គាល់គេទេ
ដូចថាគេមកគេអូសកង់រកេសរកាស់មកយើងសុំគេកូនគេប៉ុនៗៗយើង
នឹងតូចៗៗជាងយើងអីនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ សុំគេនឹងខ្ញុំអោយខោអាវគេអស់3កំប្លេអាខោអាវលេងកាត់ចូលឆ្នាំហើយបែកនឹង

ក៖ បាទអ៊ុំបាទ?

ខ៖
ខ្ញុំអោយគេបានគេកែឈ្មោះអោយយើងទៅយើងមានសិទ្ធិទៅតាមផ្លូវអត់មានពួកគេហៅពួករំដោះ សាក់មះមិត្តគេនឹងហោស គេអត់មានបាញ់យើងទេគេអោយយើងទៅតាមដំណើរ
ហើយអ្នកដៃរគ្មាននឹង ឆ្លងនឹងបាញ់ដួលនឹងកន្លែង

ក៖ អូ៎!!ខ្លាំងហាសណាអ៊ុំ?

ខ៖ វាដាក់ក្នុងត្រូលចឹងហាសអូន នរណាហ៊ានឆ្លងឈើនឹងបាញ់ទំលាក់ជ្រោះ

ក៖ អូ៎!!វាជាប់នឹងជ្រោះនឹងតែម្តងនឹង?

ខ៖ ទុកនៅក្នុងជាតិលេខមួយនឹងជ្រោះជ្រៅហាសណាស់
ទើបតែឥឡូវនឹងទេអូនស្គាល់ដែរអី

ក៖ ថ្នល់ជាតិលេខមួយនឹងដូចជា?

ខ៖ ផ្លូវទៅខេត្តស្វាយរៀងនឹង

ក៖ ប៉ុន្តែផ្លូវទៅស្វាយរៀងនឹងដូចជាគ្មានទេ?

ខ៖ ទេឥឡូវនឹងលែងមានហើយនឹង

ក៖ អូ៎!!បាទអ៊ុំ?

ខ៖ មានតែកាលពីជំនាន់អាពតទេ

ក៖ អូ៎!!ចឹងទេហោសអ៊ុំ?

ខ៖ ព្រៃកាបាសមានជ្រោះដូចជាលូនឹងអូន ដុះដូចល្អងចឹងដុះចឹង

ក៖ បាទអ៊ុំបាទ?

ខ៖ វាបាញ់ទំលាក់ជ្រោះចឹង

ក៖ អូ៎!!ខ្លាំងហាសណអ៊ុំ?

ខ៖ ពួកវានឹងខ្ញុំប្រាប់ទៅដល់ពេលដែរខ្ញុំមានអានឹងខ្ញុំទៅទៅដល់នឹងយ៉ាងម៉េចទេអូន
ខ្ញុំមិនដឹងថារស់នៅជាមួយកូនគេយ៉ាងម៉េចទេ
ខ្ញុំកំព្រាហើយមិនដឹងថាគេធ្វើបាបយ៉ាងម៉េចទេ
ខ្ញុំរត់ចេញពីគេចឹងបានបានមកនៅជាមួយឪពុកចិញ្ចឹម
ចិញ្ចឹមរហូតទាល់តែយើងមានប្តីគាត់ចែកគេចែក អាករចឹងទៅណាស់អូន
ទាល់តែគាត់ស្លាប់អស់យូរហើយនឹង

ក៖ ប៉ុន្តែពេលជំនាន់ពលពតនឹងអ៊ុំអាយុប៉ុន្មានដែរទៅ?

ខ៖ ខ្ញុំអាយុ18ឆ្នាំមិនដឹងរឺក៏អាយុ17ឆ្នាំមិនដឹងទេអូន

ក៖ ប៉ុន្តែមិនទាន់មានគ្រួសារទេណអ៊ុំ?

ខ៖ អត់ទាន់មានទេបែកហើយពីព្រោះបែកហើយនឹងខ្ញុំអាយុ19-20ឆ្នាំហើយនឹងឆ្នាំ1979-1980 ដូចជា20-21ឆ្នាំហើយយ៉ាងនឹងពីព្រោះអីខ្ញុំការនៅឆ្នាំ1982ហោស

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាបងប្អូនរបស់អ៊ុំគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ អូយអូនអើយរៀបរាប់មិនឈ្នះទេ

ក៖ វាមានច្រើនពេកហោសអ៊ុំ?

ខ៖ វាមានច្រើនពេកនឹងអាវៃនឹងត្បូងចបផង អាពន្លឺចកាប៉ាល់ផង

ក៖ នៅជំនាន់ពលពតនឹងហោសអ៊ុំ?

ខ៖ នៅជំនាន់ពលពតនឹងវាយកធ្វើម៉ាមអស់ហើយ
ហើយយាយនឹងចេះរត់ពីយើងនៅព្រៃកថ្មីនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ ពីព្រៃកថ្មីនឹងទៅរស់នៅខេត្តស្វាយរៀងនឹងរស់តែយាយមួយនឹងទៅ
ហើយអ្នកនៅនឹងហើយអ្នកដែរ
នឹងចងចាំប្រស់យើងយកទៅវៃចោលអីនៅបាត់ដំបងអីហោស

ក៖ អ្ហូ!!ចឹងហោស?

ខ៖ វាមិនវៃនៅគគិតធំនឹងទេ

ក៖
ប៉ុន្តែបងប្អូនរបស់អ៊ុំនឹងអ៊ុំមានចងចាំឈ្មោះពួកគាត់ពួកគាត់នឹងមានឈ្មោះអីគេខ្លះដែរទេអ៊ុំ?

ខ៖ ខ្ញុំចាំបានតែចាស់ៗៗទេប៉ុន្តែស្លាប់ៗៗនឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ មានឈ្មោះយាយហាន តាសំមោបដៃរអ្នកស្លាប់នឹងហាស

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ឈ្មោះបងភីបងសកតែកូនគាត់ពីរនាក់ឈ្មោះមីងស្រី
បងងុយគេចេញរួចកាលពីមុនបែកអូនគេទៅ ប្រទេសក្រៅ

កៈ អូ៎!!គេរួចផុតហើយណាអ៊ុំ?

ខៈ គេផុតហើយគេមានបានហើយ
មិនដឹងថាគេនៅណាយើងក៏មិនដែរទៅរកទៅនាំគេណាស់អូន

កៈ បាទអ៊ុំបាទ?

ខៈ ចប់អស់ចឹងទៅ

កៈ ចុះអ៊ុំគិតថាបងប្អូនរបស់អ៊ុំនឹងសព្វថ្ងៃគាត់នៅណាដែរអ៊ុំ?

ខៈ អត់មានផងនឹង

កៈ អត់មានទេណាអ៊ុំ?

ខៈ អត់មានផងនឹង

កៈ ចឹងមានន័យថានៅតែអ៊ុំមួយទេ?

ខៈ នៅតែខ្ញុំមួយទេ

កៈ ចុះអ៊ុំកាលពីក្មេងនឹងអ៊ុំនមានដែរលេងអីជាមួយបងប្អូនរបស់អ៊ុំទេអ៊ុំ?

ខៈ អត់លេងតែកាលពីយើងនៅភ្នំពេញទេអូន

កៈ បាទអ៊ុំបាទ?

ខៈ នៅភ្នំពេញនឹងយាយលេង

កៈ លេងអីគេដែរអ៊ុំ?

ខៈ
លេងជាមួយបងប្អូនដែរខ្ញុំថាស្លាប់នឹងលេងដូចជាប៉ុន្តែដូចជាពួកខ្ញុំនឹងដូចជាមិនលេងអីទេ
លេងបិទពួន លេងទៅរៀនដេញចាប់គ្នាអីតែប៉ុណ្ណឹងទេ

កះ ដល់ពេលលេង?

ខះ រត់ទៅដល់ស្តាតអូឡាំពេចនឹង

កះ បាទៗៗអ៊ុំ?

ខះ នឹងកាលពីនៅតូចៗៗនឹងមានប៉ុណ្ណឹង

កះ បាទអ៊ុំ ចុះអ៊ុំគិតថាឪពុករបស់អ៊ុំនឹងឈ្មោះអីគេដែរអ៊ុំ?

ខះ អត់ស្គាល់ទាំងអស់នឹងអូន

កះ ចឹងម្តាយរបស់អ៊ុំក៏អត់ស្គាល់ឈ្មោះដែរ?

ខះ ម្តាយរបស់ខ្ញុំនឹងឈ្មោះអន ហើយយាយបង្កើតខ្ញុំនឹងឈ្មោះហែន

កះ នឹងយាយបង្កើតខាងម្តាយរឺមួយក៏ខាងឪពុកដែរអ៊ុំ?

ខះ
យាយបង្កើតខាងម្តាយហើយយាយតាខាងឪពុកនៅក្នុងភូមិណុងដែរប៉ុន្តែខ្ញុំអត់ចាំនាមត្រកូលគេទេណាស់អូន

កះ អ៊ូ!!បាទអ៊ុំបាទ?

ខះ ខ្ញុំចាំតែយាយយើងទេនៅជាមួយយាយយើងនឹង

កះ អ៊ូ!!បាទអ៊ុំបាទ?

ខះ កំសត់ណាស់អូនអើយ

កះ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ទេចឹង?

ខះ អត់ផងនឹង

កះ ចឹងខាងម្តាយនឹងអ៊ុំស្គាល់តែឈ្មោះទេ?

ខះ ស្គាល់តែឈ្មោះទេនឹង

កះ ហើយឈ្មោះនឹងស្គាល់តែម្នាក់ទៀតណាអ៊ុំ?

ខ៖ ស្គាល់គ្រប់គ្នានឹងអូនស្គាល់មើលយាយរបស់ខ្ញុំនឹងឈ្មោះហៃន
តារបស់ខ្ញុំនឹងឈ្មោះគីង មីងរបស់ខ្ញុំនឹងឈ្មោះយំ
មីងមួយទៀតឈ្មោះយ៉ានមានតែប៉ុណ្ណឹងទេ

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ ហើយម៉ែរបស់ខ្ញុំនឹងឈ្មោះអនដែរស្លាប់នឹងហាស

ក៖ បាទអ៊ុំបាទ?

ខ៖ មានតែប៉ុណ្ណឹងអូន

ក៖ ចុះអ៊ុំគិតថាឪពុករបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ ទោះយើងអត់ដឹងផងនឹង

ក៖ ចឹងអត់ដឹងទេណា?

ខ៖ អត់ដឹងតែម្តងនឹង

ក៖ ចុះម្តាយរបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖ គាត់រកស៊ីយើងធម្មតានឹងអូន

ក៖ អូ៎!គាត់រកស៊ីធម្មតាទេហោសអ៊ុំ ចុះឪពុករបស់អ៊ុំគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖ ចា៎!!ថាម៉េច?

ក៖ ឪពុករបស់អ៊ុំនឹងគាត់ស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖ ចុះបើមិនដែរឃើញឪពុកផងនឹង

ក៖ អូ៎!!បាទអ៊ុំបាទ?

ខ៖ មិនដឹងថាយ៉ាងម៉េចផងនឹង

ក៖ ប៉ុន្តែម្តាយរបស់អ៊ុំស្លូតរឺមួយក៏កាចដែរអ៊ុំ?

ខ៖ គាត់ស្លូតទេអូន ម្តាយរបស់ខ្ញុំនឹងគាត់ស្លូតទេនឹងអត់កាចទេ

កៈ បាទអ៊ុំបាទ
ចុះអ៊ុំគិតថាកាលពីក្មេងនឹងអ៊ុំមានធ្លាប់បានធ្វើអីគេខ្លះជាមួយឪពុកម្ដាយរបស់អ៊ុំទេ?

ខៈ អត់បានធ្វើអីទេ

កៈ ដូចជាលេងអីជាមួយគ្នាហាស?

ខៈ ពីព្រោះឪពុកម្ដាយរបស់ខ្ញុំនឹងអត់បានថាអីអោយខ្ញុំ
ហើយខ្ញុំនឹងក៏មិនបានរស់នៅបានកក់ក្ដៅផងនឹង

កៈ អូ៎!!បាទអ៊ុំ ចុះ?

ខៈ ជីវិតឯកោ

កៈ ប៉ុន្តែម្ដាយរបស់អ៊ុំគាត់មិនធ្លាប់ប្រាប់ពីប្រវត្តិកាលពីអ៊ុំនៅក្មេងទេ?

ខៈ ទោះយើងនៅតូចពេកនឹងចឹងគាត់មិនបានរាយរាប់ប្រាប់យើងទេ

កៈ បាទអ៊ុំបាទ?

ខៈ យើងនៅពីមួយឆ្នាំឡើងនឹងធ្វើម៉េចបានអូនបើយើងដូចថា បើយើងបានអាយុ8-10អីចឹងទៅម្ដាយ របស់យើងដូចថាអាចរាយរាប់ប្រាប់បានហាស

កៈ បាទអ៊ុំបាទ?

ខៈ ចឹងយើងនៅតូចពេកចឹងយើងនៅនិយាយប៉ុន្មានក៏យើងវាអត់

កៈ យើងអត់ចងចាំដែរ?

ខៈ យើងអត់ចងចាំដែរនឹងនិយាយទៅប្រាប់ថាទេទាំងអស់តែម្ដងនឹង

កៈ ចឹងអ៊ុំគិតថាដូចជាយាយតាខាងឪពុកអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ អត់ទេ

កៈ ចុះយាយតាខាងម្ដាយវិញ?

ខៈ នឹងស្គាល់តែខាងម្ដាយនឹង

កៈ ចុះអ៊ុំមករស់នៅទីក្រុងភ្នំពេញនឹងយូរនៅអ៊ុំ?

ខ៖ នឹងខ្ញុំទើបតែមកនៅឆ្នាំ1974ទេមកនៅភ្នំពេញនឹងវាសុទ្ធតែបងប្អូនយាយរបស់ខ្ញុំទេ

ក៖ បាទអ៊ុំបាទ?

ខ៖ សុទ្ធតែបងប្អូនខាងយាយរបស់ខ្ញុំទេចាស់ៗៗអីនឹងបងប្អូនរបស់គាត់ទាំងអស់នឹង
តែខ្ញុំនឹងដូចថាខ្ញុំនឹងកូនម៉ែខ្ញុំចឹង យើងស្គាល់តែពូ
ស្គាល់តែមីងអីចឹងហាសមិនមែនសាច់ញៀងបង្កើតទេ វាចឹងហាសអូន

ក៖ បាទអ៊ុំបាទ?

ខ៖ ជីដូនមួយអីចឹងទៅ ជីទួតមួយអីចឹងទៅ

ក៖ ចុះអ៊ុំមានបងប្អូនណាដែររស់នៅក្រៅប្រទេសទេអ៊ុំ?

ខ៖ គេទៅពីរនាក់ដែរប៉ុន្តែមិនដឹងថាគេទៅណាអីណាផងនឹង
អូនគ្រាន់តែដឹងថាដឹងដំណឹងថាបែកហើយ
នឹងគេនៅអាមេរិចពីរនាក់គ្រាន់តែដឹងប៉ុណ្ណឹងទេ
ហើយយើងមិនដែរបានសោយសុខលុយដុល្លាអីគេដែរ

ក៖ បាទចឹងអ៊ុំ?

ខ៖ បងប្អូននឹងជីដូនមួយហើយនឹង

ក៖ ប៉ុន្តែអ៊ុំអត់ដឹងថាគាត់ទៅធ្វើអីគេដែរនៅណុងទេ?

ខ៖ យើងអត់ដឹងថាគាត់ទៅធ្វើអីហើយ គាត់ប្រកបមុខរបរអីចឹងទេណាស់

ក៖ បាទអ៊ុំបាទ?

ខ៖ យើងទៅស្រីមួយនឹងប្រុសមួយចឹងហាសណាស់

ក៖ បាទអ៊ុំ ចុះអ៊ុំគិតថាស្វាមីរបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខ៖ ខ្ញុំស្វាមីងរបស់ខ្ញុំនឹងគាត់ឈ្មោះផល្លា

ក៖ គាត់ឈ្មោះផល្លា ចុះអ៊ុំមានចងចាំថ្ងៃដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេ?

ខ៖ វាខ្ញុំការនៅឆ្នាំ1982អូន

កៈ នៅឆ្នាំ1982ណាអ៊ុំណា?

ខៈ ចាំ!!វាមិនបានជាចងចាំទេអាហើយខ្ញុំនឹងក៏បែកបាក់គ្នារហូតទៅនឹង

កៈ អូ៎!!បាទអ៊ុំ
ចឹងពេលដែរអ៊ុំរៀបអាពាហ៍ពិពាហ៍ជាមួយអ៊ុំប្រុសនឹងគិតថាអ៊ុំជាអ្នករៀបចំដោយចិត្តឯង
រឺឪពុកម្តាយជាអ្នករៀបអោយ?

ខៈ ឪពុកម្តាយជាអ្នករៀបអោយ ម្តាយចិញ្ចឹមនឹងឪពុកចិញ្ចឹមរបស់ខ្ញុំជាអ្នករៀបអោយ

កៈ អូ៎!!បាទដូចជាយើងមិនដែរបានឃើញគ្នាណាហីពីមុនហាសអ៊ុំ?

ខៈ ឃើញតើអូននៅភូមិជាមួយគ្នានឹងហាស

កៈ អូ៎!!ស្រលាញ់គ្នានឹងនៅភូមិជាមួយគ្នាណាអ៊ុំ?

ខៈ នៅភូមិនឹងអត់មានស្រលាញ់ផងនឹង

កៈ ឪពុកម្តាយរបស់អ៊ុំ?

ខៈ ក្មេងសម័យយាយនឹងអត់ចេះស្រលាញ់គ្នាផងនឹង ស្រេចលើកឪពុកម្តាយតែម្តងនឹង

កៈ ឪពុកម្តាយគាត់ជាអ្នករៀបចំអោយតែម្តងទៅ?

ខៈ គាត់អ្នករៀបចំអោយតែម្តងអូន

កៈ អូ៎!!ចឹងបាទអ៊ុំបាទ?

ខៈ គ្រាន់តែថាគាត់ប្រកែកយើងនិយាយតែបួនទៅដប់ម៉ាត់ទៅ
យើងមិនហ៊ានប្រកែកនឹងគាត់តែម្តងនឹង
អត់សោះនឹងអត់ស្រលាញ់ទេអត់ស្រលាញ់ទេអូនប្តីដែរយាយយកនឹងគឺអត់ស្រលាញ់ទេ

កៈ អូ៎!!បាទអ៊ុំ ចុះអ៊ុំគិតថាអ៊ុំចេះភាសាធ្លាប់រៀនទេអ៊ុំ?

ខៈ ខ្ញុំរៀនដែរប៉ុន្តែគ្រាន់តែខ្ញុំចេះតិចតួចស្រះអ ស្រះអានឹងអូន

កៈ អ៊ុំរៀនបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខៈ អូនអើយកាលពីជំនាន់ណុងរៀនបានថ្នាក់ទីប៉ុន្មាន៣ បើរៀនផងរត់សង្គ្រាមផងនឹង

កៈ អូ៎!!បាទៗៗអ៊ុំ?

ខៈ
កាលពីជំនាន់យាយហាសអូនឯងដឹងស្រាប់ហើយបើអូនឯងមិនជឿនឹងទៅសួរចាស់ៗៗ
ទៅ គ្មានបានអង្គុយរៀននៅក្នុងថ្នាក់នៅក្នុងសាលាដូចក្មេងឥឡូវនឹងទេអូន
ដាក់សសរម្ទូលៗៗចូលខ្ទាំងចូល ហើយរត់ទៅសិស្ស

កៈ ចឹងអត់សូវបានរៀនទេណាអ៊ុំ?

ខៈ អត់សូវបានរៀនទេ

កៈ បាទអ៊ុំ ចឹងកាលពីជំនាន់ណុងអ៊ុំមានបានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខៈ អត់មានចេះផងនឹង

កៈ ភាសាបារាំង ភាសាថៃអីក៏អត់ចេះដែរ?

ខៈ អត់អត់ចេះទេ
អត់ទាំងអស់នឹងទោះបីតែខ្មែរនឹងបើអក្សរក៏ចេះតែដូចខ្ញុំថាចឹងចេះតែត្រឹមកុមារដ្ឋាន
នឹងហាស

កៈ ប៉ុន្តែអ៊ុំកាលពីអ៊ុំរៀននឹងអ៊ុំរៀននៅណាដែរអ៊ុំ?

ខៈ រៀននឹងនៅខាងកំពង់ឆ្នាំងណុងនៅខេត្តកំពង់ឆ្នាំងក៏ខ្ញុំរៀន
ដល់មកអាពតនឹងរៀននៅខេត្តស្វាយរៀងចុះយើងនៅតូចដែរហាស

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ អាពតគេបង្រៀនដែរតើ!!!

កៈ ប៉ុន្តែបាទប៉ុន្តែអ៊ុំមានមិត្តភក្តិស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខៈ
អត់ខ្ញុំបែកហើយនឹងខ្ញុំមានមិត្តភក្តិមួយគេស្រលាញ់ខ្ញុំហាសគេប្រជាជនថ្មីដែរខ្ញុំនៅណុង
ហាសអូន

កៈ បាទអ៊ុំបាទ?

ខ៖  ប៉ុន្តែអូនអើយគេមានពេកខ្ញុំមានប្តីហើយគេក៏មិនដឹងថាមានប្តីហើយរឺក៏អត់មានទេ
ដល់ពេលគេទៅពី
ទីក្រុងភ្នំពេញនឹងទៅលេងស្រុកជានឹងប៉ុន្តែមិនមែននៅភូមិជាមួយគ្នាទេគេនៅភូមិខាងជើង

ក៖  ប៉ុន្តែនៅខេត្តស្វាយរៀងដូចគ្នាណាអ៊ុំ?

ខ៖  ចា៎!!ទាល់ហើយគេសួររកខ្ញុំហើយខ្ញុំក៏ឈរងាកមុខចេញទៅហាស
គេគេចុះពីកូនឡានតូចមួយនឹង មកម៉ែឪគ្រួសាររបស់គេនឹងហាស

ក៖  បាទអ៊ុំបាទ?

ខ៖
ស្រលាញ់គ្នាណាស់អូនបាយចឹងខ្ញុំទុកអោយវានឹងវាហូបរហូតនឹងពួកវាបានអីតែពីរនាក់ទេ
ហើយ ដេកនឹងខ្លាចគេយកទៅវៃចោលទៀត

ក៖  អូ៎!!ចឹងហោសអ៊ុំ?

ខ៖  នៅក្នុងក្រុមកុមារហាសអូនដល់ចឹងបែកហើយនឹងវាមកភ្នំពេញខ្ញុំនៅស្រែ
ទៅវាចេះតែដាច់រយះគ្នា
ចឹងទៅដល់ពេលទទួលដល់យើងមានប្តីមានអីចឹងទៅក៏វានៅនេះវាមិនដឹងថាវាមានប្តីរឺក៏
នៅទេ វាបានចតឡាននៅលើមុខថ្នល់ជាតិនឹងខ្ញុំនៅលក់នឹង
ដល់ខ្ញុំនៅលក់គេសួរដូចភ្លេចមុខខ្ញុំចឹងហាស

ក៖  បាទអ៊ុំបាទត្រូវអ៊ុំ?

ខ៖  គេសួរចាស់ៗៗថាអ៊ុំៗៗសំណាងនៅនឹងរឺក៏អី ហើយខ្ញុំឈរគេចមុខចេញ

ក៖  ម៉េចបានគេចមុខចេញពីគេ?

ខ៖  ខ្មាស់គេនឹង

ក៖  គេមានជាងហោសអ៊ុំ?

ខ៖  គេអូនខ្ញុំថាស្រែដៃគេនឹងប៉ុនៗៗអាកងកែវនឹងហាសអូន
ប៉ុនៗនឹងគេមានណាស់អូនអើយ
គ្រាន់តែសួររកនឹងយើងមិនដឹងថាបានរត់ទៅណាទេយើងវារត់មិនទាន់ក៏ឈរគេចមុខចេញ

ទៅគេណុង ក៏អន់ចិត្តទៅនឹងស្រលាញ់គ្នាណាស់អូនណាស់
គេក៏អន់ចិត្តទៅគេក៏វៀងខ្លួនចឹងទៅ
ហើយយើងនឹងក៏វៀងខ្លួនទៅខ្ញុំមិនដែរមានពួកម៉ាក់អីផងនឹង

កៈ អូ៎!!បាទអ៊ុំបាទ
ចុះអ៊ុំគិតថាអ៊ុំតាំងពីក្មេងរហូតមកដល់ពេលនេះនឹងតើអ៊ុំធ្លាប់បានធ្វើការងារអីគេខ្លះដែរនៅក្នុងជីវិតរបស់អ៊ុំដែរ?

ខៈ អើរអ៊ុំគ្មានធ្វើអីទេមានតែធ្វើការងារនៅជំនាន់អាពតនឹងលំបាកតែម្តងនឹង

កៈ និយាយរួមទៅអ៊ុំធ្វើការងារតែនៅក្នុងអាពតដែរអ៊ុំបានរៀបរាប់មិញនឹងហោស?

ខៈ
ចា៎!!រៀបរាប់មិញនឹងគឺពីនៅក្មេងមកនៅវ៉ៃយដែរជាតិត្រូវការដូចក្រសួងអីចឹងហាសអ៊ុំអត់មានតែម្តង

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ មានតែវែកដីលើកភ្លឺស្រែរើសអាចម៍គោនឹងស្ទូង ជីកប្រឡាយ

កៈ អ៊ុំធ្វើចឹងៗៗណាអ៊ុំ?

ខៈ នឹងហើយអូនដេកនៅក្នុងបង្គឹក៏មានដែរអូនម៉ោង10-12យប់ហាស

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ ឆ្អែតណាស់អូន

កៈ
ចុះអ៊ុំគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់អ៊ុំចេះលេងឧបករណ៍ភ្លេងដែរទេ?

ខៈ អត់ផងនឹង

កៈ ចឹងអត់មានទេណាអ៊ុំ?

ខៈ អត់មានទេ

កៈ ចុះផ្ទះរបស់អ៊ុំនឹងមានលក្ខណៈបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ តែខ្ញុំពីក្មេងនឹងផ្ទះរៀងធំ ដល់ពេលឥឡូវនឹងផ្ទះរៀងតូចនឹងអូនអត់ទាន់បានធ្វើផងនឹង

ក៖ ប៉ុន្តែនរណាគេជាអ្នកសាងសងផ្ទះមួយនឹងដែរអ៊ុំ?

ខ៖ កាលដែរណុងគ្រួសាររបស់ខ្ញុំដែរនៅនឹងហាស

ក៖ អូ៎!!ប៉ុន្តែពួកគាត់ចេះធ្វើផ្ទះទេអ៊ុំ?

ខ៖ គាត់ចេះធ្វើផ្ទះយើងនៅធម្មតានឹងហាស
គាត់ចេះធ្វើអូនគ្រាន់តែម៉ាធ្វើនៅជាងៗៗគ្នាយើងនឹងហាស

ក៖ ប៉ុន្តែមានដឹងថាគេមានប្រើឧបករណ៍អីសំរាប់សំរាប់សាងសងទេអ៊ុំ?

ខ៖ យាយមិនដឹងផងយាយមិនដែររៀនខាងនឹងផងតែគេប្រុសៗៗនឹងអូន

ក៖ អូ៎!!បាទអ៊ុំបាទ
ចុះអ៊ុំគិតថាអ៊ុំមានធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរទេអ៊ុំនៅស្រែចំការហាស?

ខ៖ ទៅនៅខាងខ្ញុំនឹងវាមានស្រែ

ក៖ ប៉ុន្តែអ៊ុំទៅធ្វើអីគេដែរនៅស្រែចំការនឹង?

ខ៖ ទៅច្រូតនឹងអូន

ក៖ ច្រូតណាអ៊ុំណា?

ខ៖ ចា៎!!ពេលដែរខែច្រូតនឹងយើងច្រូតទៅ ពេលដែរខែស្ទូងនឹងយើងក៏ស្ទូងទៅនឹង

ក៖ ចុះអ៊ុំគិតថាអ៊ុំធ្លាប់បើកមុខអាជីវកម្មរបរអីទេ?

ខ៖ ខ្ញុំអត់បើកលក់ដូរអីទេតែខ្ញុំមានគ្រួសារមកនឹងប្តីរបស់ខ្ញុំនឹងគាត់ធ្វើត្នោត

ក៖ បាទអ៊ុំបាទ?

ខ៖ រំងាស់ស្ករហើយខ្ញុំនឹងអ្នកដើររើសអូសដុតនឹងទេ ដូចថាអាចម៍គោនឹងសំរាមនឹងទេ

ក៖ បាទអ៊ុំបាទ?

ខ៖ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់នឹងយើងនៅខេត្តហាសអូន

កៈ ចឹងអ៊ុំចិញ្ចឹមច្រើនដែរហោសអ៊ុំ មានចិញ្ចឹមមាន់ជ្រូក?

ខៈ មានចិញ្ចឹមជ្រូក នឹងគោចឹងទៅ

កៈ ប៉ុន្តែចិញ្ចឹមលក្ខណៈខ្នាតធំរឺមួយក៏ចិញ្ចឹមលក្ខណៈធម្មតាដែរអ៊ុំ?

ខៈ
ហ៉ោ!!យើងចិញ្ចឹមនឹងខ្នាតធំដែរប៉ុន្តែមិនមែនធំអីខ្លាំងទេគ្រាន់តែមានតែបួនប្រាំរឺបួនដប់ចុះអីនឹង

កៈ អូ៎!!បាទអ៊ុំបាទ?

ខៈ មានតែប៉ុណ្ណឹងទេ បិទស្រាចិញ្ចឹមជ្រូកប៉ុណ្ណឹងអូន

កៈ ចុះអ៊ុំចេះច្រៀងទេអ៊ុំ?

ខៈ អត់ចេះទេ

កៈ អូ៎!!អ៊ុំអត់ចេះទេណាអ៊ុំ ចុះគិតថាជំនាញអីគេដែរអ៊ុំចេះស្ទាត់ជំនាញដែរអ៊ុំ?

ខៈ ហីពៅអត់មានស្ទាត់ជំនាញអីមួយផងនឹងទទេ

កៈ អូ៎!!ចឹងហោស ចុះអ៊ុំគិតថាជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរអ៊ុំ?

ខៈ មានការផ្លាស់ប្តូរច្រើនណាស់អូន

កៈ មានអីគេខ្លះដែរទៅអ៊ុំ?

ខៈ កាលពីមុននឹងប្តីរបស់ខ្ញុំនៅនឹងរៀងមាន ដល់មកគេប្រហិនប្រហើយចុងក្រោយមកគេមានស្រីមានញីទៀតទៅនឹង ដល់ទៅគេក៏ប្រហិនប្រហើយទៅក៏យើងធ្លាក់ខ្លួនក្រចឹងទៅមានការផ្លាស់ប្តូរមកក្រវិញនិយាយទៅ

កៈ បាទអ៊ុំបាទ ចុះអ៊ុំគិតថាម្ហូបអីដែរអ៊ុំចូលចិត្តពិសារដែរអ៊ុំ?

ខៈ ខ្ញុំអត់មានថាចងចាំម្ហូបមួយណាទេអូន ធម្មតានឹងម្ហូបអីក៏ហូបដែរ

កៈ អូ៎!!បាទអ៊ុំបាទ ចុះអ៊ុំគិតថាល្បែងប្រជាប្រិយ៍អីដែរអ៊ុំចូលចិត្តលេងតាំងពីក្មេងហាសអ៊ុំ?

ខៈ ថាជំនាន់ខ្ញុំនឹងគ្មានល្បែងអីដែរអាចចូលចិត្តលេងបានទេអូន

កៈ  អ៊ូ!!បាទអ៊ុំបាទ?

ខៈ  មានតែភាពតឹងណែន

កៈ  មានភាពជូរចត់ណាអ៊ុំ?

ខៈ
ចា៎!!ល្វីជូចត់នឹងនិយាយចេះតែម្តងនឹងគ្មានដូចក្មេងឥឡូវនឹងមានសិទ្ធិសេរីល្បែងទៅណាអីនឹង

កៈ  ចង់ធ្វើអីក៏បានដែរ?

ខៈ  អត់ទេអត់ទេនឹង

កៈ  ចុះអ៊ុំគិតថាអ៊ុំឆ្លងកាត់ឧបសគ្គទាំងអស់នឹងដោយរបៀបណាដែរអ៊ុំ?

ខៈ  លំបាកណាស់អូន លំបាកណាស់លំបាកមែនទែននឹងលំបាកស្ទើរតែថា

កៈ  អត់ដឹងថាធ្វើយ៉ាងម៉េចចេញណាអ៊ុំ?

ខៈ  ស្ទើរតែថានឹងមិនបានរស់មានជីវិតបានប៉ុននេះផងនឹង

កៈ  បាទអ៊ុំបាទ?

ខៈ  និយាយចេះតែម្តងទៅទាល់មានពេលណាដែរសប្បាយទៅ មានតែត្បូងចបហាស

កៈ  បាទអ៊ុំបាទ?

ខៈ  មានតែយកទៅបាត់នឹងវៃទំលាក់រណ្តៅ មានតែវៃក្បាលនឹងប្រណុង
ដល់ចឹងយើងអត់មានហើយដឹង តែចឹងដឹងតែពលកម្មទៅធ្វើជីកដីទេអូន

កៈ  អ៊ូ!!ចឹងហោសអ៊ុំ?

ខៈ  ជីកដីស្មានឹងអីឡើងហូនិយាយទៅនាំតែឈឺ

កៈ  អ៊ូ!!មានរឿងច្រើន?

ខៈ  និយាយទៅមានរឿងច្រើនណាស់ មានតែរឿងការលំបាកទេ
គ្មានសប្បាយរីករាយអីទេអូន

កៈ ចឹងអ៊ុគ្មានការសប្បាយរីករាយសូម្បីតែពេលការក៏ដោយអីក៏ដោយ?

ខៈ
ទេការហើយនឹងបានយើងផុតពីអាពតហើយនឹងយើងរីករាយនឹងគេដែរភាគច្រើននឹងរាំវង្ស
នឹង

កៈ បាទអ៊ុបាទ?

ខៈ មានតែប៉ុណ្ណឹងទេ

កៈ អ៊ុចេះរាំណាអ៊ុ?

ខៈ ហាសហាចេះតែរាំងនឹងគេនឹងឯងទៅនឹង

កៈ អ៎ូ!!បាទ
ចុះអ៊ុគិតថាកាលពីក្មេងអ៊ុធ្លាប់មានក្តីស្រម៉ៃថាពេលដែរធំឡើងនឹងអ៊ុចង់ធ្វើអីគេដែរទេអ៊ុ?

ខៈ ខ្ញុំកាលពីក្មេងហើយ ចុះយើងនៅតូចនឹងយើងចេះតែស្រម៉ៃហើយណាស់
យើងឃើញគេទៅរៀននៅ ស្រុកមិនទាន់មានបញ្ហាងីនឹងហាសអូន

កៈ បាទអ៊ុបាទ?

ខៈ ស្រម៉ៃខ្ញុំនឹងស្រម៉ៃលេងតែធ្វើជាគ្រូទេនឹង

កៈ ចឹងមានន័យថាអ៊ុចូលចិត្តធ្វើជាគ្រូណាអ៊ុ?

ខៈ ចា៎!!នឹងហើយធ្វើគ្រូ
ឃើញឡគេទៅរៀនចឹងហើយឃើញអ្នកគ្រូគេធ្វើខ្លួនទៅបង្រៀនចឹងហាស

កៈ បាទអ៊ុបាទ?

ខៈ ខ្ញុំស្រម៉ៃថាខ្ញុំអត់មានស្រម៉ៃអីទេនឹង ខ្ញុំស្រម៉ៃថាអញ់ខំរៀនអោយចេះទៅ
អញ់បានធ្វើជាគ្រូមានតែ ប៉ុណ្ណឹងទេនឹងហាស

កៈ បាទអ៊ុ
ចុះបើសិនជាចង់អោយអ៊ុផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗនឹងអ៊ុចង់ផ្ដែផ្ដាំអីទៅពួកគាត់ដែរ
អ៊ុ?

ខ៖  ខ្ញុំសព្វថ្ងៃនឹងខ្ញុំផ្ដែផ្ដាំយ៉ាងទន់ខ្សោយជាទីបំផុតនឹងអូន
ពីព្រោះយើងនឹងចេះយើងផ្ដែផ្ដាំកូននឹងថា ខំរៀនទៅ
ម៉ែរកក៏ដោយលំបាកប៉ុណ្ណាក៏ដោយនឹង
ខំបានលុយទៅរៀននឹងទៅរៀនអោយច្បាស់ជារៀន

ទោះបីយើងមិនបានធ្វើរដ្ឋមន្ត្រីធំដុំអីក៏ដោយនឹងហាសអោយតែបានចេះ
មើលបានអាចមើលរៀនសូត្របានដូចថាយើងរៀន
ស្គាល់ភាសាអីទៅបន្តិចបន្តួចអីចឹងទៅយើងអាចធ្វើ បានចឹងហាស

ក៖  បាទអ៊ុំយើងអាចបង្រៀនអីបានដែរទៅ?

ខ៖  នឹងហើយវាចឹងតើ!!យើងអាចគេរើសធ្វើអីពីព្រោះសង្គមនេះគេត្រូវការមនុស្សចេះដឹង

ក៖  បាទអ៊ុំបាទ?

ខ៖  មិនមែនដូចជាសង្គមអ៊ុំទេ

ក៖  បាទអ៊ុំបាទនឹង?

ខ៖
ហើយខ្ញុំសូមផ្ដែផ្ដាំកូននឹងសព្វថ្ងៃមានកូនប្រុសមួយនឹងខ្លាចតែអាញៀននឹងតែម្ដងនឹងអូន

ក៖  អូ៎!!អ្វីដែរអ៊ុំខ្លាចណាអ៊ុំណា?

ខ៖
ចា៎!!ខ្ញុំខ្លាចណាស់អូនពីព្រោះឃើញអ្នកដែរហូបគ្រឿងញៀននឹងវាអត់មានប្រយោជន៍អីទេ

ក៖  បាទអ៊ុំត្រូវហើយនឹង?

ខ៖  វាមានតែស្លាប់ជាជនអនាថាណាស់

ក៖
ចឹងប្រហែលជាចុងក្រោយខ្ញុំអរគុណអ៊ុំដែរបានពិភាក្សាជាមួយអ៊ុំនឹងដែរគាក់ទងពីប្រវត្តិរបស់អ៊ុំ

ខ៖  ចា៎ៗ!!នឹងហើយ

ក៖  ចឹងហាសអ៊ុំ បាទអរគុណច្រើនអ៊ុំ៕៕៕